INTERNET ARCHIVE WaybackMachine
https://www.oknha.news/social-eco/31511 Go
1 capture
15 Jan 2025
DEC JAN FEB
2024 15 2025 2026
About this capture


















# រោងចក្រផលិតស៊ីម៉ងត៍ល្បីៗចំនួន ៥ កំពុងប្រកួតប្រជែងក្នុងទីផ្សារកម្ពុជា

សង្គម និងសេដ្ឋកិច្ច

ថ្ងៃសៅរ៍ ០៥ មិថុនា ២០២១ ឧកញ៉ាកោះក្របី'

**វិស័យសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងលំនៅដ្ឋានកំពុងមានការរីកលូតលាស់ជាខ្លាំង បើទោះស្ថិតក្នុងស្ថានភាពនៃវិបត្តិកូវីដ១៩ ដែលជាហេតុបណ្តាលឲ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ ក្នុងនោះប្រទេសកម្ពុជាក៏មានការធ្លាក់ចុះផងដែរ។**

*សូមចុច Subscribe* Channel Telegram Oknha news *គ្រប់សកម្មភាពឧកញ៉ា សេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហគ្រិនភាព*

សូមចុច Subscribe Telegram oknha_news ដើម្បីទទួលបានព័ត៌មានគ្រប់សកម្មភាពឧកញ៉ា អាជីវកម្ម ចែករំលែកជោគជ័យ



សម្រាប់ក្រុមហ៊ុនដែលវិនិយោគលើវិស័យឧស្សាហកម្មស៊ីម៉ងត៍ កំពុងតែជំរុញការបង្កើនផលិតភាព និងគុណភាពស៊ីម៉ងត៍ ខណៈដែលតម្រូវការនៅតែស្ថិតនៅក្នុងអត្រាខ្ពស់ ទោះបីជាស្ថិតនៅក្នុងស្ថានភាព កូវីដ១៩យ៉ាងណាក្តី។

បច្ចុប្បន្ននេះ កម្ពុជាមានរោងចក្រផលិតស៊ីម៉ងត៍ធំៗចំនួន៥ ដែលមានសមត្ថភាពផលិតស៊ីម៉ងត៍បានចំនួនប្រមាណ៧លានតោនក្នុងមួយឆ្នាំ។ រោងចក្រទាំងនោះរួមមាន៖ **រោងចក្រស៊ីម៉ងត៍កំពត រោងចក្រស៊ីម៉ងត៍ចក្រីទីង, រោងចក្រស៊ីម៉ងត៍ ជីបម៉ុង អ៊ិនស៊ី, រោងចក្រស៊ីម៉ងត៍ បាត់ដំបង ខនស៍ ស៊ីមេន និងរោងចក្រស៊ីម៉ងត៍ ថៃ ប៊ុនរ៉ុង ខមភេនី។**

**១.ក្រុមហ៊ុន Kampot cement co.,Ltd**

ផុសថ្មីៗ

- ថាមពលអគ្គិសនី នៅតែដើរតួយ៉ាងសំខាន់ក្នុងពាណិជ្ជកម្ម របស់ឡាវ នៅឆ្នាំ២០២៤
- ពានរង្វាន់បាល់ទាត់ វិមានសំណាងលីគ ឆ្នាំ២០២៤ របស់ ឧកញ៉ាបណ្ឌិត គីម ហ៊ាង ឈានដល់វគ្គផ្តាច់ព្រ័ត្រ ក្រោយចំណាយពេលប្រកួតជិត៣ខែ
- សម្តេចធិបតី ហ៊ុន ម៉ាណែត ជំរុញឱ្យរួមគ្នាកសាងសហគមន៍កសិកម្មទំនើប ដើម្បីធានាទីផ្សារទុកជាមុន
- ឥណ្ឌូណេស៊ី គ្រោងដាក់សំណើទៅសហរដ្ឋអាមេរិក ដើម្បីកាត់បន្ថយពន្ធពាណិជ្ជកម្មលើទំនិញរបស់ខ្លួន
- អតិថិជន បុរីឡេងណាវ៉ាត្រា ទទួលអង្ករហូប១ឆ្នាំពេញដោយឥតគិតថ្លៃ អ្នកឧកញ៉ា ឡេង ណាវ៉ាត្រា ប្រកាសជួយទិញស្រូវ1000តោន ពីកសិករ កិនអង្ករចែកជូនអតិថិជនគម្រោង6A

កំពត ស៊ីមេន គឺជាក្រុមហ៊ុនផលិតស៊ីម៉ងត៍ធំជាងគេនៅកម្ពុជា។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៥ ជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ៩២.៥: ៧.៥ រវាងក្រុមហ៊ុន សៀមស៊ីម៉ងត៍ (Siam Cement) និងក្រុមហ៊ុន ខូវ ជូលី គ្រុប (Khaou Chuly Group Cambodia) ដែលជាក្រុមហ៊ុនសំណង់និងវិស្វកម្មកំពូលនៅកម្ពុជា។

Kampot cement មានរោងចក្រផលិតស៊ីម៉ងត៍របស់ខ្លួននៅខេត្តកំពត ហើយចាប់ផ្តើមដំណើរការនៅខែកុម្ភៈឆ្នាំ ២០០៨ និងមានសមត្ថភាពផលិត ៩៥០,០០០ តោនក្នុងមួយឆ្នាំ។

### ២. ក្រុមហ៊ុន Chip Mong Insee Cement Corporation

ក្រុមហ៊ុន ជីបម៉ុង អ៊ិនសេអ៊ីសស៊ីប៉ែរស៊ីខេ (CCIC) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ដោយការបណ្តាក់ទុនរួមគ្នាដែលមានតម្លៃ ២៦២ លានដុល្លារអាមេរិក។ ៦០% ត្រូវបានចាក់បញ្ចូលដោយក្រុមហ៊ុន CHIP MONG GROUP ជាសាជីវកម្មដ៏ធំបំផុតមួយនៅប្រទេសកម្ពុជាដែលមានបទពិសោធជាង ៣០ ឆ្នាំនៅក្នុងវិស័យសំណង់។ ចំនួន ៤០% ទៀតបានមកពីក្រុមហ៊ុន THAI SIAM CITY CEMENT CORPORATION មានទីស្នាក់ការកណ្តាលនៅប្រទេសថៃ ក្រុមហ៊ុនមានបទពិសោធជាង ៥០ ឆ្នាំដោយមានរោងចក្រស៊ីម៉ងត៍ **នៅប្រទេសថៃ បង់ក្លាដែស ស្រីលង្កា និងវៀតណាម**។

ជីបម៉ុង Insee មានរោងចក្រ នៅខេត្តកំពត ចម្ងាយ ១២៥ គីឡូម៉ែត្រខាងត្បូងរាជធានីភ្នំពេញ។

### ៣. ក្រុមហ៊ុន Cambodia Cement Chakrey Ting Factory Co., Ltd



រោងចក្រស៊ីម៉ង់ត៍ កម្ពុជាចក្រីទីង ត្រូវបានផ្តួចផ្តើមបង្កើតឡើងកាលពីឆ្នាំ២០១៤ ក្រោមទុនវិនិយោគប្រមាណជា ១០០ លានដុល្លារអាមេរិក ស្ថិតក្នុងភូមិភ្នំតូច ឃុំកណ្តាល ស្រុកទឹកឈូ ខេត្តកំពត លើផ្ទៃដីប្រមាណជា ៣២ ហិកតា។ រោងចក្រនេះអាចមានសមត្ថភាពផលិតស៊ីម៉ងត៍បានដល់ ១,២២ លានតោនក្នុងមួយឆ្នាំដើម្បីផ្គត់ផ្គង់តម្រូវការដែលកំពុងកើនឡើងនៅក្នុងវិស័យសំណង់នៅកម្ពុជា។

### ៤. ក្រុមហ៊ុនបាត់ដំបង ខនស៍ ស៊ីមេន



ក្រុមហ៊ុន Battambang Conch Cement Company Limited បានចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំ២០១៨ នៅខេត្តបាត់ដំបង។ រោងចក្រនេះ បានទាញយកប្រយោជន៍ពីវិស័យសំណង់ដែលកំពុងរីកចម្រើនកម្ពុជា ប្រមាណ ២៣០ លានដុល្លារអាមេរិក។

រោងចក្រ ស៊ីម៉ងត៍បាត់ដំបងខនចច (Battambang Conch Cement Factory) ដែលលាតសន្ធឹងលើផ្ទៃដីជាង ៣១៦ ហិកតានៅក្នុងស្រុករតនៈមណ្ឌល នឹងអាចផលិតស៊ីម៉ងត៍បាន ២ លានតោនក្នុងមួយឆ្នាំ

រោងចក្រនេះគឺជាការបណ្តាក់ទុនរួមគ្នារបស់ក្រុមហ៊ុន ខុនស៊ី អ៊ិនធឺណេសិនណល ស៊ីខនធីង មានមូលដ្ឋាននៅប្រទេសចិន China-based Conch International Holding (HK) និងក្រុមហ៊ុន ខេធីស៊ីធីស៊ីម៉ងត៍ ខូអិលធីឌី (Battambang KT Cement Co., Ltd) ដែលគ្រប់គ្រងដោយពាណិជ្ជករក្នុងស្រុក លោកឧកញ៉ា វិញ ហួរ និងលោកឧកញ៉ា គង់ ទ្រី។

### ៥. ក្រុមហ៊ុន ស៊ីម៉ងត៍ ថៃ ប៊ុនរ៉ុង ខមភេនី លីមីធីត

ក្រុមហ៊ុន Thai Boom Roong Cement Co.,Ltd ជារោងចក្រផលិតស៊ីម៉ងត៍ក្រោមការវិនិយោគ ១១០លានដុល្លារ នៅខេត្តកំពត បានដំណើរការជាផ្លូវការកាលពីឆ្នាំ២០១៩ ដោយអាចផលិតបាន ១ លានតោនក្នុង ១ឆ្នាំ។

រោងចក្រនេះក្លាយជារោងចក្រស៊ីម៉ងត៍ទី ៥ នៅក្នុងប្រទេសកម្ពុជា ដើម្បីជាការឆ្លើយតបទៅនឹងការអភិវឌ្ឍយ៉ាងរហ័សនៃវិស័យសំណង់។

រោងចក្រនេះត្រូវបានអភិវឌ្ឍលើផ្ទៃដី ៦៧៨,៤ ហិកតា ក្នុងស្រុកដងទុង ខេត្តកំពត ដោយរោងចក្រនេះស្ថិតលើផ្ទៃដីទំហំ ៩១ ហិកតា ជាមួយនឹងទុនវិនិយោគប្រហែល ១១០ លានដុល្លារ ជាការវិនិយោគរួមរវាងក្រុមហ៊ុនក្នុងស្រុក ថៃ ប៊ុនរ៉ុង ស៊ីម៉ងត៍ និងវិនិយោគិនចិន។

បើតាមការបញ្ជាក់ពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល លោក ស៊ុយ សែម ធ្លាប់ប្រាប់អ្នកសារព័ត៌មានឲ្យដឹងថា ត្រឹមចុងឆ្នាំ ២០១៩ កម្ពុជាមានរោងចក្រស៊ីម៉ងត៍៥ ដែលស្រូបយកបុគ្គលិកប្រហែល ២ ៧០០ នាក់ និងអាចមានសមត្ថភាពការផលិត ៨ លានតោន ជាមួយនឹងទុនវិនិយោគចំនួន ៨០០ លានដុល្លារ៕

Tagged រោងចក្រស៊ីម៉ងត៍ ជីបម៉ុង អ៊ិនស៊ី | រោងចក្រស៊ីម៉ងត៍ ថៃ ប៊ុនរ៉ុង ខមភេនី | រោងចក្រស៊ីម៉ងត៍ បាត់ដំបង ខនស៍ ស៊ីមេន | រោងចក្រស៊ីម៉ងត៍កំពត | រោងចក្រស៊ីម៉ងត៍ចក្រីទីង

## អត្ថបទទាក់ទង

លោក សេដ្ឋា ថាវីស៊ីន ថ្លែងអំណរគុណពលករកម្ពុជាដែលបានទៅធ្វើការនៅប្រទេសថៃបានរួមចំណែកដល់សេដ្ឋកិច្ចរបស់ថៃ

ថ្ងៃព្រហស្បតិ៍ ២៨ កញ្ញា ២០២៣ ឧកញ៉ាកោះក្របី




អាជ្ញាធរខេត្តបាត់ដំបង ប្រកាសរៀបចំកែលម្អរង្វង់មូលលោកតាដំបងក្រញូង ឲ្យសមនឹងទីកន្លែងសក្ការៈ

ថ្ងៃអង្គារ ២៣ សីហា ២០២២ រ៉េត សុភធា




នៅប្រទេសជប៉ុនឯណោះ កំពុងដេញថ្លៃគម្រោងសាងសង់ប្រព័ន្ធទឹកកខ្វក់នៅរាជធានីភ្នំពេញ

ថ្ងៃចន្ទ ១២ មេសា ២០២១ ឧកញ៉ាសម្រែ

តាមដានគេហទំព័រឧកញ៉ាញូស៍ ដំណឹងគ្មានដែនកំណត់
អំពី លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា មហាសេដ្ឋីលើពិភពលោក សេដ្ឋកិច្ច
អចលនទ្រព្យ ពាណិជ្ជកម្ម សហគ្រិនភាព និងកិច្ចសម្ភាសធុរជនល្បីៗ

### ទំនាក់ទំនងផ្សព្វផ្សាយពាណិជ្ជកម្ម

អាស័យដ្ឋាន: ភូមិដើមស្លែង ១ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
Email: oknmediasale@gmail.com
Tel: 078 699 299 / 070 451 400

© oknha.news